**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ទីស្ដីការគណៈរដ្ឋមន្ត្រី**

**លេខ :** ១៣៤៧ សសណ.ស

ថ្ងៃ អង្គារ ៨ រោច ខែ កត្តិក ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី ៥ ខែ ធ្នូ ឆ្នាំ២០២៣

**ឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី**

**សូមជម្រាបជូន**

**ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី**

**ឯកឧត្តម លោកជំទាវ រដ្ឋមន្ត្រីគ្រប់ក្រសួង ស្ថាប័ន**

**រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី**

**កម្មវត្ថុ៖** ស្ដីពីការផ្ដល់ជូនបណ្ណរថយន្តសម្រាប់ចូល-ចេញក្នុងបរិវេណទីស្ដីការគណៈរដ្ឋមន្ត្រីឆ្នាំ២០២៤។

សេចក្ដីដូចមានក្នុងកម្មវត្ថុខាងលើ ខ្ញុំសូមគោរពជម្រាបជូន ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីគ្រប់ក្រសួង ស្ថាប័ន រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី មេត្តាជ្រាបថា បណ្ណរថយន្តសម្រាប់ចូល-ចេញ បរិវេណទីស្ដីការគណៈរដ្ឋមន្ត្រីឆ្នាំ២០២៣ នឹងអស់សុពលភាពប្រើប្រាស់នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣។ សម្រាប់ឆ្នាំ២០២៤ខាងមុខនេះ ទីស្ដីការគណៈរដ្ឋមន្ត្រីបានរៀបចំបោះពុម្ពបណ្ណរថយន្តចូល-ចេញថ្មី(គ.រ.ម) ដើម្បីផ្ដល់ជូនក្រសួង ស្ថាប័នពាក់ព័ន្ធ ដែលមានភារកិច្ចមកទំនាក់ទំនងការងារជាមួយទីស្ដីការគណៈរដ្ឋមន្ត្រី។ ក្នុងន័យនេះ ដើម្បីធានាបាននូវសណ្ដាប់ធ្នាប់ និងសុវត្ថិភាព សូម ឯកឧត្តម លោកជំទាវ គ្រប់ក្រសួង ស្ថាប័ន ពាក់ព័ន្ធមានតម្រូវការអាចលើកសំណើស្នើសុំបណ្ណរថយន្ត(គ.រ.ម) ដោយបញ្ជាក់អំពី៖ ឈ្មោះ ឋានៈ តួនាទី ផ្លាកលេខ និងប្រភេទរថយន្ត ដែលត្រូវទទួលយកបណ្ណទៅប្រើប្រាស់ ចាប់ពីថ្ងៃជូនដំណឹងនេះតទៅ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម ឯកឧត្តម លោកជំទាវ ជ្រាបតាមការគួរ។

**ឧ.រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី**

**រដ្ឋលេខាធិការប្រចាំការ**

**ចម្លងជូន៖**

- ខុទ្ទកាល័យឯកឧត្តម ឧបនាយករដ្ឋមន្ត្រីប្រចាំការ
- គ្រប់ក្រសួង ស្ថាប័ន
- ឯកសារ កាលប្បវត្តិ

បណ្ឌិតសភាចារ្យ **ហ៊ីង ថូរ៉ាក់ស៊ី**